

# ប្រវត្តិនៃការចងក្រងវចនានុក្រមខ្មែរ

## (រៀបរាប់ដោយលោក ហ្សក សេដែស)

ស្រាវជ្រាវដោយ

**សុន តុលា**

និស្សិតច្បាប់នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង

ឆ្នាំ ២០១៦




# ប្រវត្តិនៃការចងក្រងវចនានុក្រមខ្មែរ

## (រៀបរាប់ដោយលោក ហ្សក សេដែស)

ស្រាវជ្រាវដោយ

សុន តុលា

និស្សិតច្បាប់នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង

ឆ្នាំ២០១៦

ចងក្រងដោយ: សុន តុលា (និស្សិតច្បាប់នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង)

ដកស្រង់ចេញពីគេហទំព័រ http://www.dahlina.com/general-knowledge/khmer-dictionary-history.html

# ប្រវត្តិនៃការចងក្រងវចនានុក្រមខ្មែរ (រៀបរាប់ដោយលោក ហ្សក សេដែស)

ដោយយល់ឃើញថា លោកអ្នកខ្លះ ដែលមានស្នាដៃជាច្រើន នៅក្នុងការជួយឲ្យវចនានុក្រម លេចចេញជារូបរាងឡើង តែត្រូវខ្មែរយើងបំភ្លេចចោល ខ្ញុំសូមលើកយកកូនអត្ថបទមួយ ដែលចុះក្នុង**ព្រឹត្តិបត្រសាលាបារាំងចុងបូព៌ា ឆ្នាំ១៩៣៨ ភាគ ៣៨ លេខ ១** សរសេរដោយលោក **ហ្សក សេដែស អ្នកប្រាជ្ញបុរាណវិទ្យា** និង**ប្រវត្តិវិទ្យាអាស៊ីអាគ្នេយ៍** មកចុះផ្សាយបន្ត។ អត្ថបទនេះសរសេរជាភាសាបារាំង ដែលខ្ញុំបានបកប្រែជាខ្មែរ។ ដូច្នេះ បើមានកំហុសលើការសរសេរឈ្មោះ ឬងារនៃបុគ្គលណាម្នាក់ជាខ្មែរ សូមអ្នកអានជួយកែតម្រូវផង។



លោក ហ្សក សេដែស

## អត្ថបទសរសេរដោយលោក សេដែស មានដូចតទៅ៖

ខ្ញុំសូមរៀបរាប់ដោយលំអិត ពីការរៀបចំវចនានុក្រមខ្មែរថ្មី ដែលក្នុងគ្រាដែលភាគពីរបោះពុម្ពចប់ វចនានុក្រមនេះ នឹងក្លាយជាស្នាដៃមួយដែលពេញលេញ។ ខ្ញុំសូមផ្តល់តែទិដ្ឋភាពខាងក្រៅខ្លះៗ នៃការងារសព្វថ្ងៃនេះ និងទៅលើរបៀបដែលវចនានុក្រម

នេះ បានរៀបចំឡើងតែប៉ុណ្ណោះ។ សៀវភៅនេះត្រូវតែបានតាក់តែងឡើងជាភាសាខ្មែរទាំងស្រុង។

ពាក្យនីមួយៗត្រូវបានបោះពុម្ពដោយអក្សរត្រង់។ ក្នុងករណីមានការសង្ស័យ លើការអានពាក្យ របៀបអានត្រូវបានបញ្ជាក់ក្នុងវង្វង់ក្រចក។ ប្រភេទវេយ្យាករណ៍ បង្ហាញជាអក្សរកាត់។ ប្រភពពាក្យត្រូវបានបញ្ជាក់ចំពោះគ្រប់ពាក្យ មិនមែនមានប្រភពមកពីពាក្យខ្មែរ។ ចុងក្រោយ គឺនិយមន័យពាក្យ និងការបង្ហាញពីកន្សោមពាក្យនានា ដែលប្រើប្រាស់ពាក្យនោះ។ លំដាប់លំដោយពាក្យ គឺរៀបតាមអក្សរខ្មែរ ដែលជាលំដាប់លំដោយតួអក្សរសំស្ក្រឹត។ អ្នកនិពន្ធវចនានុក្រម ត្រូវបង្ខំចិត្តបញ្ចូលគ្រប់ពាក្យ ដែលក្លាយមកពីពាក្យសំស្ក្រឹត និងបាលី ដែលគេនៅតែប្រើប្រាស់នៅឡើយនៅកម្ពុជា ; តាមរយៈការសារភាពដ៏ហូរហែរ ដោយផ្ទាល់របស់ពួកគេ អ្នកនិពន្ធគួរតែរង្កៀសចិត្ត ចំពោះចំណុចមួយទៀតវិញច្រើនជាង ដោយសារថា ពួកគេបានបញ្ចូលពាក្យ ដែលមិនទាន់មានប្រើប្រាស់នៅឡើយ ប៉ុន្តែពួកគេគិតថា ពាក្យទាំងនោះនឹងត្រូវយកមកប្រើប្រាស់។

អារម្ភកថា ដែលមិនមានចុះហត្ថលេខា ប៉ុន្តែទំនងជាតាក់តែងឡើង ដោយគណៈកម្មការវចនានុក្រម បានសន្មតថា ការតាក់តែង និងការបង្កើតនៃការងារចងក្រងពាក្យដ៏ធំសំបើមនេះ ដែលប្រភេទការងារនេះ ធ្វើឡើងជាលើកដំបូងនៅក្នុងប្រទេសកម្ពុជា មានកំណើតឡើងតាមរយៈ**រាជក្រឹត្យចុះថ្ងៃទី ១០ កញ្ញា ១៩២៩**។ ត្រង់នេះមានការកែប្រែការពិតមួយ ដោយចេតនា ឬអចេតនា ដែលបណ្តាលឲ្យខ្ញុំ មិនអាចទ្រាំបានដោយមិនធ្វើការកត់សម្គាល់ និងក្រើនរំលឹកពីហេតុការណ៍ខ្លះៗ បានឡើយ។

**រាជក្រឹត្យចុះថ្ងៃ១០ កញ្ញា ១៩២៩** នេះ ដែលតាមការរៀបរាប់របស់អារម្ភកថា មើលទៅហាក់ដូចជាការបង្កើតគណៈកម្មការវចនានុក្រម តាមពិតមានគោលបំណងគ្រាន់តែដើម្បីកែប្រែសមាសភាពរបស់គណៈកម្មការ ទទួលបន្ទុកកែពង្រាងវចនានុក្រម តែប៉ុណ្ណោះ ដែលគណៈកម្មការនេះ ត្រូវបានកំណត់ឡើងរួចមកហើយ ដោយ**រាជក្រឹត្យចុះថ្ងៃ**

**ទី៣០ វិច្ឆិកា ១៩២៧**។ តាមរយៈការសង្កេតនេះ យើងឃើញថា កំណើតវចនានុក្រមនេះ បានកើតឡើងមុន**ឆ្នាំ១៩២៩** ដោយសារថានៅ**ឆ្នាំ ១៩២៧** គេបានត្រៀមបោះពុម្ព និងកែវចនានុក្រមពុម្ពរួចទៅហើយ។

តាមពិតទៅ ការចាប់ផ្ដើមការងារបានប្រព្រឹត្តិឡើង កាលពី១៤ឆ្នាំមុនមកម្ល៉េះ ដែលអារម្ភកថានេះមិននិយាយដល់ ហើយអារម្ភកថានេះ សមតែចាត់ទុកជាគំនូសលាតត្រដាងនៃផ្ទាំងក្ដោង ដែលបិទបាំងបំភ្លេចជាពិសេសនូវអ្វី ដែលបានធ្វើឡើងមុន**ឆ្នាំ១៩២៩** ឆ្នាំនៃការបង្កើត**វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ**នៅភ្នំពេញ។

ដើម្បីបង្កើតជាស្នាដៃប្រវត្តិសាស្ត្រ ដែលមិនលំអៀង ខ្ញុំសូមបំភ្លេចចោលសិននូវអ្វីដែលខ្ញុំបានចូលរួម ក្នុងការបង្កើតវចនានុក្រមនេះឡើង និងសូមសង្ខេបតែលើឯកសាររក្សានៅ**សាលាបារាំង**។ ប៉ុន្តែនេះ គឺជាឯកសារដំបូង ដែលឋិតក្នុងក្រសែភ្នែករបស់ខ្ញុំ គឺជាកូនលិខិតមួយ សរសេរដោយខ្ញុំផ្ទាល់ដៃ ក្នុងថ្ងៃដើម**ខែមិថុនា ១៩១៥** តាមរយៈការស្នើសុំពិមិត្តភក្តិកម្ពុជារបស់ខ្ញុំជាច្រើននាក់ សរសេរទៅកាន់នាយករបស់ខ្ញុំ **លោក ល្វីស ហ្វីណូត៍** ដើម្បីទទួលបានការយល់ព្រម។ « ខ្មែរបានប្រាប់, ខ្ញុំសរសេរ, និងស្នើសុំជាយូរមកហើយនូវគណៈកម្មការមួយ ប្រមូលផ្តុំឡើង ដើម្បីបង្កើតវចនានុក្រមខ្មែរមួយឡើង-ចងក្រងឡើងតាមបែបវចនានុក្រមរបស់បណ្ឌិត្យសភាបារាំង–ដែលកំណត់អក្ខរាវិរុទ្ធតែមួយ សម្រាប់ប្រើប្រាស់ក្នុងភាសារបស់ពួកគេ »។ ហើយខ្ញុំបានរៀបរាប់ពីគំនិតរបស់ខ្ញុំ ក្នុងការបង្កើតគណៈកម្មការនេះឡើង និងកម្មវិធីការងាររបស់ពួកគេ។

**ថ្ងៃទី ១៦ មិថុនា លោក ហ្វីណូត៍** បានឆ្លើយមកខ្ញុំថា « ផែនការរបស់លោក ខ្ញុំយល់ឃើញថា បានធ្វើឡើងបានយ៉ាងត្រឹមត្រូវ ហើយខ្ញុំគ្មានអ្វីជំទាស់ទៅនឹងផែនការនេះដែរ។ រីឯភាពបានការនៃការងារនេះវិញ យើងមិនត្រូវសង្ស័យទេថា ៖ ភាពគ្មានសណ្តាប់ធ្នាប់នៃអក្ខរាវិរុទ្ធ ដែលអ្នកចារចម្លងធ្វើតាមតែចិត្តនឹកឃើញ និងដោយងងិតងងល់ បានផ្តល់ដល់ភាសាខ្មែរ នូវគុណវិបត្តិដ៏ធំមួយ ដែលច្បាស់ណាស់ថា គ្មាននរណាគេចង់លូកដៃធ្វើ

ការប៉ះប៉ូវឡើងវិញនោះទេ »។ ខ្ញុំបានបញ្ជូនលិខិតរបស់ខ្ញុំ នៅថ្ងៃ **២៧ មិថុនា** ទៅលោក **រេស៊ីដង់ស៊ុបពេរីយ៉រ បូឌាំង** ដែលបានដាក់ជូនលិខិតនេះ ទៅក្រុមប្រឹក្សារដ្ឋមន្ត្រីតាំងពីដើម**ខែកក្កដា**។ ពីរខែក្រោយមក **ព្រះបាទ ស៊ីសុវត្ថិ** បានតាក់តែងរាជក្រឹត្យខាងក្រោម ដែលយើងអាចនិយាយបានថា ជាសំបុត្រកំណើតរបស់វចនានុក្រមខ្មែរ។

យើង

ព្រះបាទសម្តេចព្រះស៊ីសុវត្ថិ ចមចក្រពង្ស ហរិរាជ បរមិន្ទរ ភូវណៃ

ក្រយកែវហ្វា សុឡាឡៃ ព្រះចៅក្រុងកម្ពុជាធិបតី ស្តេចក្រុងកម្ពុជា

-បានទ្រង់យល់ថា ភាសាខ្មែរមិនទាន់មានអក្ខរាវិរុទ្ធផ្លូវការ

-បានទ្រង់យល់ពីសារៈសំខាន់ ដើម្បីសម្រួលដល់ការសិក្សា នៃការកំណត់អក្ខរាវិរុទ្ធ និង អត្ថន័យរបស់ពាក្យ

-បានទ្រង់យល់កិច្ចព្រមព្រៀង រវាងលោករេស៊ីដង់ស៊ុបពេរីយ៉រ និងយើង

-យោងតាមសំណើរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី

ត្រាស់បង្គាប់

ប្រការ ១ – គណៈកម្មការតែងតាំងខាងក្រោមនេះ ត្រូវទទួលបន្ទុកបង្កើតវចនានុក្រមផ្លូវការនៃភាសាខ្មែរ ដែលកំណត់អក្ខរាវិរុទ្ធ ប្រភពពាក្យ និងន័យរបស់ពាក្យក្នុងភាសាខ្មែរ។

សមាសភាពគណៈកម្មការ៖

_ ឧកញ៉ាចក្រី ប៉ុណ្ណ សេនាធិបតីក្រសួងសិក្សាធិការ និងយុទ្ធនាធិការ ជាប្រធាន

_ ព្រះអង្គម្ចាស់ ភាណុវង្ស

_ ព្រះអង្គម្ចាស់ សុធារស

_ ព្រះមហារាជធម្ម សួស សង្ឃនាយកធម្មយុត្តិកនិកាយ ចៅអធិការវត្តប្រយូរវង្ស ក្រុងភ្នំពេញ

_ ព្រះវនរ័ត ចន្ទ សង្ឃនាយកមហានិកាយ វត្តឧណ្ណាលោម ក្រុងភ្នំពេញ

_ ព្រះសីលសំវរ ហាក់ សង្ឃនាយកមហានិកាយ វត្តឧណ្ណាលោម

_ អ្នកឧកញ៉ាពិភិតល្បសូរ ម៉ី សេនាបតីទីចក្រីចាស់ រ៉ឺត្រៃត

_ អ្នកឧកញ៉ាវិបុលរាជ មាស ឧបសេនាបតីក្រសួងក្សេត្រាធិការ

_ អ្នកឧកញ៉ា ស្រីធម្មាធិរាជ អ៊ុក ឧបសេនាបតីក្រសួងព្រះបរមរាជវាំង

_ អាចារ្យ អ៊ិន អ្នកបាត់ដំបង

ចងក្រងដោយ: សុន តុលា (និស្សិតច្បាប់នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង)

ដកស្រង់ចេញពីគេហទំព័រ http://www.dahlina.com/general-knowledge/khmer-dictionary-history.html

ប្រការ ២ – គណៈកម្មការតែងតាំងខាងលើ នឹងត្រូវប្រជុំគ្នារាល់ព្រឹក លើកលែងតែថ្ងៃឈប់សម្រាក នៅវត្តព្រះកែវ នៅភ្នំពេញ ក្នុងមន្ទីរដែលមានឈ្មោះថា មន្ទីរបរិយតិ។

គណៈកម្មការត្រូវតែប្រឹក្សា ជាមួយសេនាបតីក្រសួងយុត្តិធម៌របស់យើង លោកឧកញ៉ាយោមរាជឈុន ព្រមទាំងតំណាងសាលាបារាំងចុងបូព៌ា និងអាចកោះហៅគ្រប់មនុស្សទាំងអស់ ដែលមានសមត្ថភាពឲ្យចូលរួមក្នុងកិច្ចការរបស់ខ្លួន។

ធ្វើនៅព្រះបរមរាជវាំងក្រុងភ្នំពេញ នៅថ្ងៃទី៤ កញ្ញា ១៩១៥។

ស៊ីសុវត្ថិ

បានឃើញដើម្បីអនុវត្តតាម

រេស៊ីដង់ស៊ុបពេរីយ័រ

បូដ្វាំង

គណៈកម្មការដែលបានបង្កើតឡើងនេះ បានចាប់ផ្តើមការងាររបស់ខ្លួននៅ**ថ្ងៃទី៦ តុលា ១៩១៥** ក្រោមការដឹកនាំរបស់**ឯកឧត្តម ប៉ាន**។ ការប្រជុំធ្វើឡើងនៅ**វត្តព្រះកែវ** នៅក្នុងកន្លែងចាស់នៃសាលាបាលី ដែលត្រូវបានបង្កើតឡើងកាលពីឆ្នាំកន្លងទៅ និងទើបតែត្រូវបានសម្ពោធដោយ **លោកអគ្គទេសាភិបាល ROUME**។ អ្នកដែលជាសមាជិករបស់គណៈកម្មការ ដែលមិនត្រូវបានផ្តល់ងារកិត្តិយស ឬដោយហេតុផលការទូត ជាជាងបច្ចេកទេស មិនបង្អែបង្អង់យូរក្នុងការដកខ្លួនចេញ ហើយនៅសល់តែអ្នកធ្វើការល្អៗប៉ុន្មាននាក់តែប៉ុណ្ណោះ ដែលមកចូលរួមក្នុងសម័យប្រជុំប្រចាំថ្ងៃ។ ខ្ញុំសូមអនុញ្ញាតលើកឡើងអំពីអនុស្សាវរីយ៍របស់មនុស្សបួននាក់ ក្នុងចំណោមអ្នកនៅសល់ទាំងប៉ុន្មាននាក់នោះ ដែលបានទទួលមរណភាពទៅមុននឹងបានឃើញការបញ្ចប់នៃស្នាដៃមួយ ដែលពួកគេបានផ្តល់វិភាគទានយ៉ាងសំបើម។

**អ្នកឧកញ៉ាពិភិតល្បស្ងូវ ម៉ី** អតីតសេនាបតីទិចក្រី និង**អ្នកឧកញ៉ាធម្មានិករ គង់** អតីតសេនាបតីទីវាំងវរវៀងជ័យ ដែលធំដឹងក្តីក្នុងរាជ្យ**ព្រះបាទ អង្គដួង**។ លោកទីមួយ ជាមនុស្សចំណាស់រឹងប៉ឹង នៅតែស្វាហាប់នៅឡើយ និយាយច្រើន មានទេពកោសល្យខាងនិយាយស្តី និងគួរឲ្យចាប់អារម្មណ៍ជានិច្ច។

ចងក្រងដោយ: សុន តុលា (និស្សិតច្បាប់នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង)

ដកស្រង់ចេញពីគេហទំព័រ http://www.dahlina.com/general-knowledge/khmer-dictionary-history.html

លោកទីពីរ មើលពីខាងក្រៅ មិនសូវគួរឲ្យចាប់អារម្មណ៍ តែមានប្រាជ្ញាឈ្លាសវៃ ចូលចិត្តនិយាយកាត់ដោយពាក្យក្រម៉ាច់ក្រមើម នូវការនិយាយហូរហែរអួសបន្លាយរបស់សហសេវិកគាត់ និងកាត់បន្ថយនូវឥទ្ធិពលរបស់គាត់។ អ្នកទាំងពីរបានផ្ដល់ដល់គណៈកម្មការ នូវអនុស្សាវរីយ៍របស់ពួកគាត់ ពីកម្ពុជាសម័យមុនបារាំងចូលមកដល់ និងចំណេះដឹងឥតខ្ចោះភាសាខ្មែរ។

**អាចារ្យ អ៊ិន** ដែលបន្តិចក្រោយមកទទួលបានងារជាឧកញ៉ាសុត្តន្តប្រីជា ស្ទាត់ជំនាញភាសាបាលី អ្នកនិពន្ធសៀវភៅវេយ្យាករណ៍ និងកវីដែលមានកេរ្តិ៍ឈ្មោះ សិក្សានៅសាលាសៀម តែរក្សានូវគំនិតជាតិនិយម ដោយបានជួយផ្ដល់ដល់គណៈកម្មការតាមរយៈចំណេះដឹងរបស់គាត់ នូវវាក្យស័ព្ទដ៏សំបូរបែប និងការបញ្ចេញសំឡេងតាមបែបអ្នកស្រុកខ្មែរភាគខាងលិច។ គឺដោយសារតែគាត់នេះហើយ ដែលវចនានុក្រមអាចតាក់តែង នូវពាក្យជាច្រើនដែលបញ្ចប់ដោយអក្សរ "រ" ដែលពាក្យទាំងនោះ ត្រូវបានបញ្ជាក់អះអាងដោយសិលាចារិកបុរាណ និងដោយពាក្យកំចីពីខ្មែរដោយជនជាតិសៀមដែលបានបាត់បង់ពីសំដីជនជាតិខ្មែរភាគកណ្ដាល ប៉ុន្តែនៅតែមានសូរនៅឡើយនៅខាងបាត់ដំបង។

ជាបញ្ចប់ ចំពោះគ្រប់ពាក្យដែលទាក់ទងនឹងសាសនា ឬមានប្រភពមកពីភាសាបាលី គណៈកម្មការមិនរួញរាឡើយ ក្នុងការហៅជំនួយពីបច្ចេកទេស និងសមត្ថភាពរបស់សមាជិកថ្មី គឺ **ព្រះមហាវិមលធម្ម ថោង** ចាងហ្វាងទីមួយសាលាបាលីជាន់ខ្ពស់ ភិក្ខុដែលមានមុខមាត់ និងប្រាជ្ញា ដែលខ្ញុំផ្ដល់កិត្តិយសទុកស្មើជាគ្រូម្នាក់របស់ខ្ញុំ។

នេះជាវិធី ដែលពួកយើងធ្វើការ។ នៅពេលចាប់ផ្ដើមសម័យប្រជុំ លេខារបស់គណៈកម្មការ បើខ្ញុំចាំមិនខុសទេ **លោក ហាក់** សព្វថ្ងៃជាសាស្ត្រាចារ្យនៅសាលាបាលីជាន់ខ្ពស់ ក្នុងផ្លូវសាសនាមានងារជា សីលសំវរ សរសេរនៅលើក្ដារខៀនខ្មៅ តាមខ្ញុំហៅ នូវបញ្ជីពាក្យបណ្ដោះអាសន្ន ដែលត្រូវលើកយកមកពិភាក្សាក្នុងពេលប្រជុំ។ បញ្ជីនេះផ្អែកលើវចនានុក្រមខ្មែរ d'AYMONIER និងរបស់ P. GUESDON ដែលបានចាប់ផ្ដើមចេញផ្សាយបណ្ដើរៗហើយ។ បញ្ជីនេះ ត្រូវបំពេញបន្ថែមដោយគណៈកម្មការ ជាពិសេស

ដោយ**អាចារ្យ អ៊ិន** ដែលដោយសមត្ថភាពតែងកំណាព្យរបស់គាត់ ជានិច្ចកាលដោយពាក្យចួនរណ្ដំ មានសមត្ថភាពពិតប្រាកដ សមជាអ្នកតាក់តែងវចនានុក្រម។ ប្រភេទវេយ្យាករណ៍នៃពាក្យនីមួយៗ ដើមកំណើតរបស់វា និងន័យរបស់វា ត្រូវបានកំណត់ ដែលមិនត្រូវបានធ្វើឡើង ដោយគ្មានការពិភាក្សាគ្នាយ៉ាងខ្លាំងក្លា ជានិច្ចជាកាលនោះទេ៖

លោកប្រធាន ដែលមិនមែនមានសេចក្ដីចាប់អារម្មណ៍តិចតួចជាងគេ ក្នុងការជជែកពីវេយ្យាករណ៍នោះ ជួនកាលចាំបាច់ត្រូវតែតម្រូវឲ្យមានការបោះឆ្នោត ដោយលើកដៃ ដែលក្នុងនោះដោយសារខ្ញុំជាជនបរទេស និងគ្រាន់តែជាអ្នកប្រឹក្សាសាមញ្ញមួយរូប ខ្ញុំត្រូវតែអនុបវាទជានិច្ច។ នៅពេលចប់សម័យប្រជុំនីមួយៗ ពាក្យនីមួយៗដែលបានសិក្សារួច ត្រូវបានកត់ត្រាចូលក្នុងសលាកប័ត្រ។

គឺបែបនេះហើយ ដែលយើងដំណើរការពេញមួយត្រីមាសចុងក្រោយនៃ**ឆ្នាំ ១៩១៥** និងពេញមួយ**ឆ្នាំ ១៩១៦**។ បន្ទាប់ពីការចាកចេញរបស់ខ្ញុំទៅស្រុកសៀម នៅ**ខែមករា ១៩១៧** ខ្ញុំមិនបានចូលរួមចំណែកអ្វីទៀតទេ នៅក្នុងការងាររបស់គណៈកម្មការនេះ ដែលត្រូវបានបញ្ចប់ក្នុង**ឆ្នាំ ១៩២៤** ប៉ុន្តែខ្ញុំបានបន្តតាមដានការងារគណៈកម្មការ តាមរយៈសំបុត្ររបស់អតីតសហសេវិករបស់ខ្ញុំ។ ដោយសារសំបុត្រនេះ ខ្ញុំបានដឹងលឺអំពីសង្គ្រាមប៉ាកា ដែលបានកើតឡើងក្រោយកំណែទម្រង់អក្ខរាវិរុទ្ធ ដែលបានធ្វើឡើងដោយគណៈកម្មការក្នុងសម័យប្រជុំដំបូងៗ។

ថ្វីបើកំណែទម្រង់នេះ ជាចុងក្រោយ ត្រូវបានគេបដិសេធក្ដី យើងត្រូវតែនិយាយពាក្យពីរម៉ាត់ពីគម្រោងនេះ ព្រោះការប្រឆាំងដ៏សាហាវ ដែលកំណែទម្រង់នេះបានបញ្ឆោះឲ្យកើតឡើង បានបន្ទុចបង្អាក់ការបោះពុម្ពផ្សាយ ដែលគួរតែអាចត្រូវបានធ្វើឡើងកាលពី ៨ ឆ្នាំមុនមកម្ល៉េះ។

កំណែទម្រង់សំខាន់ៗ មានការលុបបំបាត់ចោលសញ្ញាក្បៀស ឬបន្តក់ ជំនួសដោយសញ្ញាសំយោគសញ្ញា ឬផាត់លើ និងការបង្កើតសញ្ញាអឌ្ឍចន្ទ (សក់ក) ដើម្បីសម្គាល់ស្រៈ អ នៅព្យញ្ជនៈនីមួយៗ។ ដូចជា កក កក់ កាក កាក់ គណៈកម្មការ ស្នើឲ្យសរសេរជា ក័ក កក កាក ក័ក (?)។ គុណប្រយោជន៍សំខាន់នៃកំណែទម្រង់នេះ គឺនៅត្រង់វាអាច

ឲ្យយើងសរសេរពាក្យត្រូវ តាមប្រភពពាក្យសំស្ក្រឹត ឬបាលី និងត្រូវតាមទម្រង់បុរាណ ដូចដែលត្រូវបានបញ្ជាក់ទទួលស្គាល់ តាមរយៈសិលាចារិក។ យោងតាមមតិរបស់ **លោក ហ្វីណូត៍** បានប្រឹក្សាជាមួយលោក វេស៊ីដង់ស៊ុបពេរីយ៉រ « ការបង្កើតអក្ខរាវិរុទ្ធថ្មីនេះ ជាការអភិវឌ្ឍដ៏ប្រសើរមួយ ដោយបានសម្រួលតួអក្សរខ្លះ ដែលស្មុគស្មាញ និងដោយបានបង្កើតភាពត្រូវគ្នា យ៉ាងសុក្រឹតរវាងពាក្យខ្មែរ និងពាក្យដើមសំស្ក្រឹត ឬបាលី។

ម្យ៉ាងវិញទៀត កំណែទម្រង់នេះ សមល្មមមិនជ្រុលហួសហេតុពេក និងមិនធ្វើឲ្យក្រឡាប់ចាក់ដល់ទម្លាប់សរសេរ ដែលមានមកពេកទេ។ ត្រង់ចំណុចខ្លះ កំណែទម្រង់នេះ សឹងតែមិនអាចនិយាយថា ជាអ្វីដែលថ្មីផង ប៉ុន្តែជាការត្រឡប់ទៅប្រពៃណីបុរាណកម្ពុជា ដែលត្រូវបានបោះបង់ដោយគ្មានហេតុផល នាយុគសម័យថ្មីៗនេះថែមទៀតផង »។

ទោះជាយ៉ាងណាក្តី កំណែទម្រង់នេះត្រូវបានធ្វើឲ្យខកខាន ដោយបាបធម៌ពីរដែលយូរ និងឆាប់បានបំផ្លាញវាឲ្យរលាយ។ សញ្ញាអឌ្ឍចន្ទ (សក់ក) ជាសញ្ញាថ្មី ដែលទម្រង់ចម្លែករបស់វា មានរាងដូចម្ជូកមិនរង់ចាំយូរទេ នៅក្នុងការបញ្ចោះឲ្យមានការចំអកឡកឡឺយកើតឡើង។ ជាពិសេស គណៈកម្មការ មិនបានប្រុងប្រយ័ត ដោយមិនបានសុំការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ដែលមានក្រុមប្រឹក្សារដ្ឋមន្ត្រី និងព្រះមហាក្សត្រ ចំពោះការបង្កើតអក្ខរាវិរុទ្ធថ្មី ដែលគណៈកម្មការបានគិតថា សមតែគេគ្រប់គ្នាពេញចិត្ត។

ការបង្កើតថ្មីនេះ បានប្រមូលផ្តុំក្រុមប្រឆាំងនានា៖ អ្នកអភិរក្សនិយមផ្តាប់មុខ (អ្នកបែបនេះមានច្រើននាក់ណាស់នៅកម្ពុជា), អ្នកដែលគិតថាខ្លួនមានសមត្ថភាព ដើម្បីចូលរួមក្នុងគណៈកម្មការ តែមិនត្រូវបានអញ្ជើញឲ្យចូលរួម និងជាបញ្ចប់គ្រប់មនុស្សទាំងអស់ ដែលប្រឆាំងដោយសារការស្អប់សមាជិកគណៈកម្មការរូបខ្លះ។ អវិភាពបណ្តាលមកពីគម្រោងកែទម្រង់ធ្លាក់លើវចនានុក្រម ធ្វើឲ្យយើងបានឃើញនៅកម្ពុជា នូវទស្សនីយភាពដ៏គួរឲ្យឈឺចាប់របស់មនុស្សមួយក្រុម ដែលខំធ្វើដើម្បីប្រយោជន៍ជាតិ តែត្រូវបរាជ័យដោយសារការច្រណែន ទំនាស់បុគ្គល និងបំណងចង់ឲ្យគេឲ្យតម្លៃជាជាងតម្លៃនៃហេតុផលរបស់អ្នកជំទាស់ទាំងនោះ។

ចងក្រងដោយ: សុន តុលា (និស្សិតច្បាប់នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង)

ដកស្រង់ចេញពីគេហទំព័រ http://www.dahlina.com/general-knowledge/khmer-dictionary-history.html

ចលនាប្រឆាំងត្រូវបានធ្វើឲ្យកក្រើកឡើង ដោយសារការចុះផ្សាយក្នុង**ឆ្នាំ១៩២០** នូវសេចក្ដីណែនាំតូចមួយ សម្រាប់ជួយសម្រួលដល់គ្រូបឋមសិក្សាកម្ពុជា ដែលត្រូវបានបោះពុម្ពផ្សាយដោយប្រើអក្ខរាវិរុទ្ធថ្មី។ ការតវ៉ាបានកើតឡើង៖ ក្រុមប្រឹក្សារដ្ឋមន្ត្រី បានប្រកាសប្រឆាំងនឹងកំណែទម្រង់។ វត្តមាននៃជម្លោះដែលហួសពីសមត្ថភាពរបស់គាត់ **លោករេស៊ីដង់ ស៊ុបពេរីយ័រ បូឌ្វាំង** បានកោះហៅជំនួយពីសាលាបារាំងចុងបូព៌ា និងបានបញ្ជូននា**ខែតុលា ឆ្នាំ ១៩២១** នូវវិវាទនេះដល់**លោក ល្វីស ហ្វីណូត៍** ដែលបានផ្ដល់យោបល់ប្រកបដោយគតិបណ្ឌិតមកវិញ ឲ្យផ្អាកការចេញសេចក្ដីណែនាំ ដែលមានជម្លោះនោះ រហូតដល់មានការអន្តរាគមន៍ណាមួយលើបញ្ហាអក្ខរាវិរុទ្ធ ហើយឲ្យអញ្ជើញគណៈកម្មការវចនានុក្រម ឲ្យធ្វើការអធិប្បាយលម្អិត និងការបកស្រាយការបង្កើតថ្មី ដែលបានលើកឡើងមកនោះ។

អ្វីៗឋិតនៅគាំងត្រឹមនោះ ហើយគណៈកម្មការបានបន្តដោយយឺតៗនូវការងាររបស់ខ្លួនរហូតដល់ **ខែកុម្ភៈ ឆ្នាំ ១៩២៤** ដែលជាកាលបរិច្ឆេទ ដែលធុរកិច្ចនៃពង្រាងវចនានុក្រមត្រូវបានបញ្ចប់ជាស្ថាពរ។ ជាពីរដងក្នុងអំឡុង**ឆ្នាំ ១៩២៤** ឯកឧត្ដមរដ្ឋមន្ត្រីអប់រំសាធារណៈ បានស្នើសុំការអនុញ្ញាតបោះពុម្ពផ្សាយ ដោយព្រមទាំងស្នើបង្កើតគណៈកម្មការថ្មី ដើម្បីត្រួតពិនិត្យការងាររបស់គណៈកម្មការដំបូង។ លោករេស៊ីដង់ ស៊ុបពេរីយ័រ គិតថា បែបបទនេះមិនមានប្រយោជន៍ ហើយសម្រេចចិត្តរាយការណ៍ ដល់ព្រះមហាក្សត្រ ហើយបានស្នើដល់ព្រះមហាក្សត្រ នៅ**ថ្ងៃទី ២១ តុលា** នូវយោបល់ផ្ទាល់របស់ទ្រង់ លើកំណែទម្រង់ដែលខាងសាលាបារាំងបានគាំទ្រ។ ដោយលិខិតចុះ**ថ្ងៃ ២៥ ធ្នូ ១៩២៤ ព្រះបាទស៊ីសុវត្ថិ** បានយល់ព្រមផ្ដល់ព្រះរាជអនុញ្ញាតដល់អក្ខរាវិរុទ្ធថ្មី និងបញ្ហាទំនងជាត្រូវបានដោះស្រាយចប់សព្វគ្រប់ រីឯការបោះពុម្ពផ្សាយទំនងជាអាចចាប់ផ្ដើមបាន។

ប៉ុន្តែនៅកម្ពុជា អ្វីៗមិនអាចទៅលឿនបែបនេះនោះឡើយ ហើយក៏មិនងាយស្រួលបែបនេះដែរ។ សំណៅដៃពង្រាងវចនានុក្រម ត្រូវបានផ្ញើដល់រោងពុម្ពអាណាព្យាបាលដោយមានអារម្ភកថា ចុះកាលបរិច្ឆេទ **កក្កដា ១៩២៥** ប៉ុន្តែបន្ទាប់ពីបានបោះពុម្ពចេញ

បានតែប៉ុន្មានទំព័រមក ការងារនោះត្រូវបានបញ្ឈប់។ រោងពុម្ពអស់ក្រដាស។ ក្រុមអ្នកប្រឆាំងនឹងកំណែទម្រង់អក្ខរាវិរុទ្ធ ឆ្លៀតពេលនេះបង្កឲ្យមានចលនាប្រឆាំងជាថ្មី។

ខ្ញុំសូមមិនរៀបរាប់ពីសង្គ្រាមតូចមួយនេះ ដែលបានកើតឡើងពេញមួយ**ឆ្នាំ ១៩២៦** ព្រោះបើដូច្នេះ ខ្ញុំត្រូវតែនិយាយដល់បុគ្គលមេៗ នៃចលនាទាំងពីរ ដែលអ្នកទាំងនោះខ្ញុំបានរាប់អាន និងគោរពយ៉ាងខ្លាំង ហើយខ្ញុំអាចប្រថុយខ្លួននឹងដាស់ឡើងវិញនូវជម្លោះ ដែលសព្វថ្ងៃនេះបានចុះថមថយរួចហើយនោះ។ ថ្វីបើអក្ខរាវិរុទ្ធថ្មី ត្រូវបានព្រះរាជអនុញ្ញាត ដោយព្រះមហាក្សត្រក្តី ក៏លោករេស៊ីដង់ស៊ុបពេរីយ័រ នៅតែយកការងារនោះទៅរាយការណ៍ដល់ក្រុមប្រឹក្សារដ្ឋមន្ត្រីដែរ។

**ថ្ងៃទី ១៩ មេសា ១៩២៦** ក្រុមប្រឹក្សារដ្ឋមន្ត្រីបានចេញក្រឹត្យថ្កោលទោសមួយហើយលោករេស៊ីដង់ស៊ុបពេរីយ័រ បូដ្វាំង បន្ទាប់ពីបានផ្ញើលិខិតទៅកាន់ក្រសួងមន្ទីរផ្សេងៗ នូវសារាចរណ៍ហាមឃាត់ ការប្រើប្រាស់អក្ខរាវិរុទ្ធថ្មី បានចេញលិខិតបញ្ឈប់ការបោះពុម្ពវចនានុក្រមនា**ថ្ងៃទី ៦ ឧសភា ឆ្នាំ ១៩២៦**។ ក្រុមប្រឆាំងបានសម្រេចគោលបំណងរបស់ខ្លួនដល់ទីបំផុត។ ប៉ុន្តែក្រុមអ្នកធ្វើសំណាងដែរ ដែលមិនបានបាត់បង់សិទ្ធិទាំងអស់របស់ខ្លួន ហើយព្រះរាជាដ៏ល្អ **ព្រះបាទស៊ីសុវត្ថិ** បានធ្វើជាសេចក្តីសម្រេចចិត្តមួយ នៅក្នុងសំបុត្រឯកជនមួយ ទៅកាន់លោករេស៊ីដង់ស៊ុបពេរីយ័រ ហើយ « ដោយយល់ពីភាពចាំបាច់នៃការកាត់សេចក្តីលើកំណែទម្រង់អក្ខរាវិរុទ្ធ ដែលស្នើឡើងដោយគណៈកម្មការ វចនានុក្រមដែលត្រូវបានប្រឆាំងដោយមជ្ឈដ្ឋានខ្លះ » ក៏ចេញ**រាជក្រឹត្យមួយចុះថ្ងៃទី ១៩ កក្កដា ឆ្នាំ ១៩២៦** មានសេចក្តីថា៖

យើង

-បានទ្រង់យល់រាជក្រឹត្យលេខ ៦៧ ចុះថ្ងៃទី ៤ កញ្ញា ១៩១៥ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការទទួលបន្ទុកបង្កើតវចនានុក្រមខ្មែរផ្លូវការ

-បានទ្រង់យល់បុព្វកថាតាក់តែងដោយគណៈកម្មការវចនានុក្រម និងបានស្នើកែប្រែលើចំណុចជាច្រើនលើអក្ខរាវិរុទ្ធប្រើប្រាស់សព្វថ្ងៃ

ចងក្រងដោយ: សុន តុលា (និស្សិតច្បាប់នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង)

ដកស្រង់ចេញពីគេហទំព័រ http://www.dahlina.com/general-knowledge/khmer-dictionary-history.html

-បានទ្រង់យល់របាយការណ៍របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដឹកនាំដោយលោករេស៊ីដង់ស៊ុបពេរីយ៉ររបស់សាធារណរដ្ឋបារាំងនៅកម្ពុជា ក្នុងសម័យប្រជុំពេញអង្គទី៤៩៨ នាថ្ងៃទី ១៩ មេសា ១៩២៦

-ដោយទ្រង់យល់ពីភាពចាំបាច់ក្នុងការកាត់សេចក្តី លើការកែប្រែអក្ខរាវិរុទ្ធ ដែលស្នើដោយគណៈកម្មការវចនានុក្រម ដែលត្រូវបានប្រឆាំងដោយមជ្ឈដ្ឋានខ្លះ

-បានទ្រង់យល់កិច្ចព្រមព្រៀងរវាងលោករេស៊ីដង់ស៊ុបពេរីយ៉រ និងយើង

-យោងតាមសំណើរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី

ត្រាស់បង្គាប់

ប្រការ ១ – គណៈកម្មការដែលមានសមាសភាព ៖

១° ឧកញ៉ាចក្រី ប៉ុណ្ណ សេនាធិបតីក្រសួងសិក្សាធិការ ជាប្រធាន

២° ព្រះមហាវិមលធម្ម ថោង ចាងហ្វាងទីមួយសាលាបាលីជាន់ខ្ពស់ សមាជិក

៣° ព្រះអមរាភេរខេត ភួង សង្ឃនាយកធម្មយុត្តិកនិកាយ សមាជិក

៤° ព្រះគ្រូសង្ឃសត្ថា ណាត សាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់ សមាជិក

៥° ព្រះសមុមហាបញ្ញា ស៊ីម សង្ឃនាយកមហានិកាយ សមាជិក

៦° ព្រះអង្គម្ចាស់ សុធារស សមាជិក

៧° ព្រះអង្គម្ចាស់ វឌ្ឍឆាយ៉ាវង្ស ប្រធានសាលាក្រុមចោទ សមាជិក

៨° ឧកញ៉ាវិបុល កាន់ ឧបសេនាធបតីក្រសួងក្សេត្រាធិការ សមាជិក

៩° ឧកញ៉ាឧត្តមភាសា អ៊ុម ប្រធានសាលាឧទ្ធរណ៍ សមាជិក

១០° ឧកញ៉ា នឿ ប្រធានសាលាឧទ្ធរណ៍ចូលនិវត្តន៍ សមាជិក

១១° ស្មៀនថ្នាក់ទី៣ មួង ឃួន នៃក្រសួងព្រះបរមរាជវាំង លេខា

ត្រូវបានគាស់អញ្ជើញ ដើម្បីប្រកាសទទួលយក ឬបដិសេធកំណែទម្រង់អក្ខរាវិរុទ្ធ ស្នើដោយគណៈកម្មការវចនានុក្រម ដែលមានក្នុងបុព្វកថារបស់គណៈកម្មការនេះ។

ប្រការ ២ – គណៈកម្មការនេះ ត្រូវតែផ្តល់សុពលភាពដល់យោបល់នានា ទាក់ទងនឹងប្រធានបទនេះ របស់កុងសីនៃរេស៊ីដង់ ក្នុងអំឡុងពេលពិភាក្សាសម្រេច ក្នុងវេលាចុងក្រោយនៃសម័យប្រជុំ។

ប្រការ ៣ – គណៈកម្មការអាចប្រឹក្សាជាមួយគ្រប់ជនទាំងអស់ ដែលគណៈកម្មការគិតថាមានប្រយោជន៍អាចប្រមូលយកទស្សនៈបន្ថែម។

ចងក្រងដោយ: សុន តុលា (និស្សិតច្បាប់នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង)
ដកស្រង់ចេញពីគេហទំព័រ http://www.dahlina.com/general-knowledge/khmer-dictionary-history.html

ប្រការ ៤ – កំណត់ហេតុសម័យប្រជុំនីមួយៗត្រូវបញ្ជូន មុនបើកសម័យប្រជុំបន្ទាប់មកទៀត ទៅកាន់គ្រប់សមាជិកទាំងអស់នៃគណៈកម្មការ ដែលត្រូវចុះហត្ថលេខា បន្ទាប់ពីបានផ្តល់សេចក្តីយល់ព្រម បើសិនជាមានលើកំណែ និងសេចក្តីបន្ថែម បើគិតថាមានប្រយោជន៍។

ប្រការ ៥ – កំណត់ហេតុនេះ ភ្ជាប់មកជាមួយនូវរបាយការណ៍សង្ខេប នៃសំណើរបស់គណៈកម្មការ នឹងត្រូវដាក់ជូនទៅក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលនឹងបញ្ជូនមកយើងនូវសេចក្តីយល់ឃើញរបស់ពួកគេ។

ធ្វើនៅព្រះបរមរាជវាំងក្រុងភ្នំពេញ នៅថ្ងៃទី១៩ កក្កដា ១៩២៦។

ស៊ីសុវត្ថិ

បានឃើញ និងដាក់ឲ្យអនុវត្ត

ដោយសារាចរណ៍លេខ ១៧៩៤ ចុះថ្ងៃទី ២៣ កក្កដា ១៩២៦

រេស៊ីដង់ស៊ុបពេរីយ៉រ

បូដ្វាំង

គណៈកម្មការថ្មី បានចំណាយពេលពីរលើក (**២៤ សីហា** និង **៨ កញ្ញា ១៩២៦**) ដើម្បីត្រួតពិនិត្យកំណែទម្រង់អក្ខរាវិរុទ្ធ និងធ្វើការសន្និដ្ឋានលើប្រធានបទនេះ ដោយបានរក្សាពីគម្រោងដើម នូវការប្រើសញ្ញាផាត់លើ តែចំពោះពាក្យដែលមានប្រភពមកពីបាលី និងសំស្ក្រឹតតែប៉ុណ្ណោះ។

ក្នុងអំឡុងពេលនោះ សភាក្នុងស្រុក បានចេញសេចក្តីប្រកាសនា**ថ្ងៃទី៣ កញ្ញា** ប្រឆាំងរាល់កំណែទម្រង់អក្ខរាវិរុទ្ធទាំងអស់ ដោយសំឡេង ៣៨ ទល់ ៦។ ក្រុមប្រឹក្សារដ្ឋមន្ត្រីក៏សម្រេចចិត្ត ក្នុងសម័យប្រជុំ **១៤ តុលា** ថា គណៈកម្មការត្រួតពិនិត្យវចនានុក្រម នឹងត្រូវប្រជុំជាមួយគណៈកម្មការអចិន្ត្រៃយ៍របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ក្រោមអធិបតីរបស់ចាងហ្វាងការិយាល័យរេស៊ីដង់ស៊ុបពេរីយ៉រ។

គណៈកម្មការចម្រុះនេះ បានប្រមូលផ្តុំគ្នាពីរថ្ងៃបន្ទាប់មក គឺ **១៦ តុលា** ហើយធ្វើការថ្កោលទោសកំណែទម្រង់ ដែលពួកគេរក្សាតែការប្រើប្រាស់ ដោយមិនបង្ខំនៃសញ្ញាផាត់លើ៖ សេចក្តីសម្រេចនេះ ត្រូវបានផ្តល់សច្ចាប័ន ក្នុងសម័យប្រជុំក្រុមប្រឹក្សារដ្ឋមន្ត្រី នា **ថ្ងៃទី២៨ តុលា**។ ដើម្បីចាប់ផ្តើមធ្វើការងារត្រួតពិនិត្យឡើងវិញនូវសំណៅដៃ និងការ

ត្រួតពិនិត្យការបោះពុម្ពវចនានុក្រម ក្រុមប្រឹក្សារដ្ឋមន្ត្រីបានតែងតាំង នា**ថ្ងៃទី៦ មករា ឆ្នាំ ១៩២៧ ព្រះគ្រូសង្ឃសត្ថា ណាត** សាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់ និង**ឧកញ៉ាសុភាធិរាជ ស៊ូ** ទីប្រឹក្សាសាលាឧទ្ធរណ៍ ក្រោមអធិបតីលោកនាយករដ្ឋមន្ត្រី។

នា**ខែមករា ១៩២៧ លោករេស៊ីដង់ស៊ុបពេរីយ័រថ្មី** LE FOL បានមកដល់ គាត់បានផ្តល់ជាថ្មីដល់អ្នកកំណែទម្រង់នូវក្តីសង្ឃឹម ដែលត្រូវបានរលត់ក្នុងពេលដ៏ខ្លីបន្ទាប់មក។ ក្នុងសម័យប្រជុំ **១៧ មិថុនា ១៩២៧** ក្រុមប្រឹក្សារដ្ឋមន្ត្រី បានប្រកាសសម្រេចលើសេចក្តីសម្រេចចិត្តលើកមុន ហើយបន្តិចក្រោយមក បានបញ្ជូនស្នើសុំព្រះហស្តលេខាពី**ព្រះបាទស៊ីសុវត្ថិ មុនីវង្ស** នូវរាជក្រឹត្យពីរ។ **រាជក្រឹត្យទីមួយ ២៩ វិច្ឆិកា ១៩២៧** « ផ្តល់សុពលភាពទាំងស្រុង ដល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ចុះ**ថ្ងៃ ២៨ តុលា ឆ្នាំ ១៩២៦, ៦ មករា** និង **១៧ មិថុនា ឆ្នាំ ១៩២៧** និងផ្តល់សុពលភាពទាំងស្រុង ដល់សំណើរបស់គណៈកម្មការត្រួតពិនិត្យវចនានុក្រមខ្មែរ ដែលមានចែងក្នុងរបាយការណ៍ ភ្ជាប់មកជាមួយនេះ របស់អង្គប្រជុំនា **ថ្ងៃទី១៦ តុលា ១៩២៦** ទាក់ទងនឹងអក្ខរាវិរុទ្ធខ្មែរ » និងដោយបញ្ជាក់ថា « អក្ខរាវិរុទ្ធដែលត្រូវបានអនុម័តនេះ ត្រូវតែជាអក្ខរាវិរុទ្ធតែមួយ ដែលប្រើប្រាស់ក្នុងលិខិតផ្លូវការ ក្នុងការបង្រៀននៅសាលានានានៃរាជាណាចក្រ និងសម្រាប់ការប្រលងប្រជែងនានា »។

រាជក្រឹត្យទីពីរ ចេញថ្ងៃបន្ទាប់ **៣០ វិច្ឆិកា** បានតែងតាំង**ព្រះគ្រូសង្ឃសត្ថា ណាត** និង **ឧកញ៉ាសុភាធិរាជ ស៊ូ** ជាអ្នកត្រួតពិនិត្យកែតម្រូវសំណៅវចនានុក្រម។

ក្នុងអំឡុងពេលពាឆ្នាំបន្ទាប់មក ការងារមិនមែនជាកំណែសំណៅវចនានុក្រម តែជាការត្រួតពិនិត្យឡើងវិញលើសំណៅដៃ ត្រូវបានបន្តជាធម្មតា នៅរាជបណ្ណាល័យក្រោមការត្រួតពិនិត្យរបស់អ្នកអភិរក្សដ៏មានភក្តីភាព **កញ្ញា** Suzanne KARPELÈS បន្ទាប់មក**លោក** DESJARDINS។ ក្នុងដំណើររបស់ខ្ញុំទៅភ្នំពេញ នា**ខែ សីហា ១៩៣១** ខ្ញុំបានឃើញថា សំណៅដៃត្រូវបានបញ្ចប់សព្វគ្រប់ រួចរាល់នឹងយកទៅបោះពុម្ព និងមិនចាំបាច់យកទៅបញ្ចុះបញ្ចូល**លោក រេស៊ីដង់ស៊ុបពេរីយ័រ** LAVIT នោះទេ ដោយសារហេតុផលថា

គេមិនត្រូវធ្វើឲ្យយឺតយូរបន្តទៀតទេ ក្នុងការបោះពុម្ពដែលគេទន្ទឹងរង់ចាំជាយូរមកហើយនោះ។

នេះហើយជាដើមកំណើត និងនេះហើយជាដំណើរប្រែប្រួលនៃស្នាដៃមួយ ដែលគេត្រូវការពេលអស់មួយភាគបួនសតវត្សរ៍ (១/៤) ដើម្បីសម្រេចឲ្យលេចចេញជារូបរាងឡើង។ ដោយសារស្នាដៃនេះ ការសិក្សាភាសាខ្មែរទទួលបានឧបករណ៍ការងារថ្មីមួយ ដែលបើវាមិនឥតខ្ចោះ ក៏អាចចាត់ទុកជាកំណត់សម្គាល់មួយ ក្នុងកាលបរិច្ឆេតនៃប្រវត្តិសាស្រ្តទស្សនវិជ្ជាឥណ្ឌូចិនដែរ។

វចនានុក្រមនេះ ត្រូវតែធ្វើឲ្យពេញលេញឡើង ដោយការស្រាវជ្រាវ ផ្នែកអក្សរសាស្រ្ត និងធ្វើឲ្យសំបូរបែបដោយពាក្យពេចន៍នានា ដកស្រង់ចេញពីស្នាដៃអក្សរសិល្ប៍បុរាណ៖ នេះនឹងត្រូវជាភារកិច្ចរបស់មនុស្សជំនាន់ថ្មី បង្កើតឡើងក្រោមការដឹកនាំរបស់គ្រូនៅសាលាបាលីជាន់ខ្ពស់។

ប៉ុន្តែជាបឋម វចនានុក្រមខ្មែរផ្លូវការ ជាស្នាដៃមួយដែលជារបស់ជាតិពិតប្រាកដទាំងក្នុងការបង្កើតវចនានុក្រមនេះ ក៏ដូចជាលទ្ធផលរបស់វា ដែលយើងបានទន្ទឹងរង់ចាំ។ វចនានុក្រមត្រូវបានចងក្រង និងតាក់តែងឡើងទាំងស្រុង ដោយអ្នកប្រាជ្ញអក្សរសាស្រ្តខ្មែរ ដែលភាគច្រើនមិនដែលទាំងស្គាល់វិទ្យាសាស្រ្តលោកខាងលិចផង និងមិនចេះពាក្យបារាំងសូម្បីតែមួយពាក្យ។

សាលាបារាំងចុងបូព៌ា មានសេចក្តីរីករាយនឹងបញ្ចេញគំនិត និងតាមដានយ៉ាងយកចិត្តទុកដាក់ ដំណើរការតាំងពីពេលចាប់ផ្តើម ដោយមិនបានដាក់កំហិតទស្សនៈរបស់ខ្លួនរហូតដល់ចុងក្រោយ ដែលរាជបណ្ណាល័យទទួលយកភារកិច្ចត្រួតត្រាលើការត្រួតពិនិត្យ និងចម្លង៕

ចងក្រងដោយ: សុន តុលា (និស្សិតច្បាប់នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង)

ដកស្រង់ចេញពីគេហទំព័រ http://www.dahlina.com/general-knowledge/khmer-dictionary-history.html